-តាមសំណើរបស់ឯកឧត្តមរដ្ឋលេខាធិការ ក្រសួងធម្មការ និង សាសនា

**សំរេច**

**មាត្រា ១** : ផ្ទេរសិទ្ធិជូនឯកឧត្តម **តុល ឡោះ** រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា ជារដ្ឋមន្ត្រីស្តីទីនៃ ក្រសួងធម្មការ និង សាសនាជំនួយឯកឧត្តម **ឈឿន វណ្ណារ័ត្ន** ត្រូវអញ្ជើញទៅបំពេញបេសកកម្មនៅបរទេសចាប់ពីថ្ងៃទី ០៧ ដល់ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៦ ។

**មាត្រា ២** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការ គ្រប់រដ្ឋលេខាធិការដ្ឋាន និងឯកឧត្តម **តុល ឡោះ** ត្រូវទទួលបន្ទុកសេចក្តីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

# II - ការងារបណ្តាក្រសួង

## ប្រកាសអន្តរក្រសួង

### ១ - អន្តរក្រសួងមហាផ្ទៃ - ការពារជាតិ

រាជធានីភ្នំពេញ ,ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ១៩៩៦

**ប្រកាសអន្តរក្រសួងលេខ ២៧៨ ប្រ.ក**

**ស្តីពីល័ក្ខខ័ណ្ឌ នៃការសុំលិខិតអនុញ្ញាតអោយប្រើប្រាស់ អាវុធ និង ជាតិផ្ទុះគ្រប់ប្រភេទ**

**សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង សហរដ្ឋមន្ត្រីក្រសួងការពារជាតិ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស រកម ០១៩៦ ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ១៩៩៣ ស្តីពីការ បង្កើតក្រសួងការពារ ជាតិ និង អគ្គសេនាធិការ នៃកងទ័ពជាតិកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស រកម ០១៩៦ ០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពី ការបង្កើតក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ១៦ អ.ន.ក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦២ អ.ន.ក្រ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រង ការប្រើប្រាស់អាវុធ និង ជាតិផ្ទុះគ្រប់ប្រភេទ
- បានឃើញការចាំបាច់របស់ក្រសួងមហាផ្ទៃ និង ក្រសួងការពារជាតិ

**សំរេច**

**ប្រការ ១** : ជនណាមានសិទ្ធិប្រើប្រាស់អាវុធខ្លីជាលក្ខណៈបុគ្គល ដូចមានចែងក្នុងមាត្រា ៨ មាត្រា ៩ និង មាត្រា ១០ នៃអនុក្រឹត្យលេខ ៦២ អ.ន.ក្រ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រង ការប្រើប្រាស់អាវុធ និងជាតិផ្ទុះគ្រប់ប្រភេទ ទើបមានសិទ្ធិធ្វើពាក្យសុំលិខិតអនុញ្ញាតប្រើប្រាស់អាវុធ មកស្ថាប័នមានសមត្ថកិច្ច និង បំពេញល័ក្ខខ័ណ្ឌតាមការកំណត់ដូចខាងក្រោមនេះ ÷

**I– កងកំលាំងនគរបាលជាតិ មន្ត្រីរាជការស៊ីវិល និង ជនស៊ីវិល**

ក– ចំពោះកងកំលាំងនគរបាលជាតិ :

-កងកំលាំងនគរបាលជាតិតាមអង្គភាពចំណុះទីស្តីការរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ត្រូវធ្វើពាក្យស្នើសុំដោយមានការបញ្ជាក់ និងចុះហត្ថលេខាទទួលស្គាល់តាមឋានានុក្រម ដើម្បីនាយកដ្ឋាននគរបាលដាក់ជូនអគ្គនាយកនគរបាលជាតិពិនិត្យ និង សំរេច ។

-កងកំលាំងនគរបាលជាតិ ចំណុះស្នងការដ្ឋាននគរបាលខេត្ត-ក្រុង ឬ អធិការដ្ឋាននគរបាលស្រុក ខ័ណ្ឌ ត្រូវធ្វើពាក្យស្នើសុំដោយបញ្ជាក់ និង ចុះហត្ថលេខាទទួលស្គាល់ពីប្រធានការិយាល័យ ឬ អធិការនគរបាលស្រុក ខ័ណ្ឌ ដើម្បីការិយាល័យជំនាញដាក់ជូនស្នងការពិនិត្យ និង សំរេច ។

ខ-ចំពោះមន្ត្រីរាជការស៊ីវិល :

-មន្ត្រីរាជការស៊ីវិលតាមក្រសួង ស្ថាប័នត្រូវធ្វើពាក្យស្នើសុំដោយបញ្ជាក់ និង ចុះហត្ថលេខាទទួលស្គាល់ ចាប់ពីថ្នាក់នាយកខុទ្ទកាល័យឡើងទៅ ដើម្បីនាយកដ្ឋាននគរបាល រដ្ឋបាល ដាក់ជូនអគ្គ នាយកនគរបាលជាតិពិនិត្យ និង សំរេច ។

-មន្ត្រីរាជការស៊ីវិលតាមខេត្ត-ក្រុង ត្រូវធ្វើពាក្យស្នើសុំដោយបញ្ជាក់ និង ចុះហត្ថលេខាទទួលស្គាល់ពីខុទ្ទកាល័យខេត្ត-ក្រុង ឬ ពីប្រធានមន្ទីរជុំវិញខេត្ត-ក្រុង ដើម្បីការិយាល័យជំនាញដាក់ជូន ស្នងការពិនិត្យ និង សំរេច ។

គ-ចំពោះជនស៊ីវិល ល័ក្ខខ័ណ្ឌនៃការសុំលិខិតអនុញ្ញាតអោយប្រើប្រាស់អាវុធ និង ជាតិផ្ទុះ គ្រប់ប្រភេទនឹងត្រូវមានការកំណត់ដោយឡែក យោលទៅតាមសំណូមពរចាំបាច់ និង មានការសំរេចពី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ឃ-អ្នកសុំត្រូវបំពេញតាមតារាងរៀបរាប់ អាវុធមានបិទតែមប្រើយ័តាមការកំណត់របស់ច្បាប់ និង រូបថត ទំហំ ៣×៤ ចំនួន ០៤ សន្លឹក (ថតចំពីមុខមិនពាក់វ៉ែនតា ចំពោះកងកំលាំងនគរបាលជាតិ រូបថតត្រូវស្លៀកពាក់ឯកសណ្ឋានមិនពាក់មួក) ។

ង-ពេលដែលបំពេញបែបបទលើតារាងរៀបរាប់រួចហើយ នាយកដ្ឋាននគរៈបាលរដ្ឋបាលត្រូវ ចេញបង្កាន់ដៃទទួលស្គាល់អាវុធបណ្តោះអាសន្នអោយសាមីជន ។ អាវុធត្រូវយកមកពិនិត្យលក្ខណៈបច្ចេកទេស នៅនាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ បើនៅក្រសួង ឬ ការិយាល័យបច្ចេកទេស បើនៅខេត្ត-ក្រុង ។

ច– គំរូលិខិតអនុញ្ញាតប្រើប្រាស់អាវុធមាន ០៤ ប្រភេទមានទំហំ ១០,៣០ សម × ៧,៥០ សម ដូចគ្នា ។

–ប្រភេទទី ១ : លិខិតអនុញ្ញាតប្រើប្រាស់អាវុធយកតាមខ្លួនរបស់នគរបាលជាតិមានពណ៌ (ស) មានរូបទង់ជាតិបញ្ជិតលើផ្ទៃខាងក្រៅ និង មានសញ្ញា (រូបសឹង្ហចំកណ្តាល) ។

–ប្រភេទទី ២ : លិខិតអនុញ្ញាតប្រើប្រាស់អាវុធអង្គភាពរបស់កងកំលាំងនគរបាលជាតិ មានពណ៌ (លឿង) ។ មានរូបទង់ជាតិបញ្ជិតពីលើផ្ទៃខាងក្រៅ និង មានសញ្ញា (រូបសឹង្ហចំកណ្តាល) ។

–ប្រភេទទី ៣ : លិខិតអនុញ្ញាតប្រើប្រាស់អាវុធយកតាមខ្លួនរបស់ស្ថាប័នស៊ីវិលមានពណ៌ (ស) មានសញ្ញារូបទង់ជាតិបញ្ជិតលើផ្ទៃខាងក្រៅ ។

–ប្រភេទទី ៤ : លិខិតអនុញ្ញាតប្រើប្រាស់អាវុធអង្គភាពរបស់ស្ថាប័នស៊ីវិលមានពណ៌ (ខៀវ) មានរូបទង់ជាតិបញ្ជិតលើផ្ទៃខាងក្រៅ ។

**II–ចំពោះកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និង កងជីវពល :**

កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និង កងជីវពល ដែលមានសិទ្ធិប្រើប្រាស់អាវុធ ជាលក្ខណៈបុគ្គល ត្រូវបានកំណត់ដូចខាងក្រោម ÷

*ចំពោះទ័ពប្រយុទ្ធ :*

–យោធិនមានសិទ្ធិប្រើប្រាស់អាវុធខ្លីបាន គឺត្រូវមានឋានន្តរសក្តិចាប់ពីនាយចំណង់ឡើងទៅ ។

*ចំពោះទ័ពបំរើការប្រយុទ្ធ :*

–យោធិនមានសិទ្ធិប្រើប្រាស់អាវុធខ្លីបាន គឺត្រូវមានឋានន្តរសក្តិចាប់ពីអនុសេនីយ៍ទោឡើង ទៅ ។

ដោយឡែកយោធិនដែលពុំទាន់មានឋានន្តរសក្តិដូចការកំណត់ខាងលើ តែអាចមានសិទ្ធិប្រើប្រាស់អាវុធខ្លីបានក្នុងករណីមានភារកិច្ចចាំបាច់ និង ត្រូវបានការអនុញ្ញាតអោយប្រើប្រាស់ជាកងឯកភាព គឺអាចអាទិភាពបានដូចជាជំនាញស្រាវជ្រាវ

ការិយាល័យទី ២ អាកាសយានិក ហិរញ្ញវត្ថុ អយ្យការ តុលាការ កងការពារថ្នាក់ដឹកនាំ ភ្នាក់ងារសារទូរលេខ និងភ្នាក់ងារផ្សេងៗ ។ ក្រៅពីការបំពេញបេសកកម្ម មិនអនុញ្ញាតអោយយកអាវុធខ្លីតាមខ្លួន ហើយត្រូវរក្សាទុកនៅផ្ទះ ឬ នៅតាមកងឯកភាពខ្លួន ។

ក្រសួងការពារជាតិ ប្រគល់សិទ្ធិការចេញប័ណ្ណប្រើប្រាស់អាវុធខ្លី ជាសមត្ថកិច្ចរបស់អគ្គសេនាធិការជាអ្នកចេញប័ណ្ណ ។ គ្រប់កងឯកភាពក្នុងកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ ត្រូវធ្វើពាក្យស្នើសុំប័ណ្ណផ្តល់អោយគ្រប់យោធិនទាំងឡាយណាដែលមានអាវុធខ្លី និងមានសិទ្ធិប្រើប្រាស់ ហើយបានបញ្ចូលចំនួនអាវុធនោះក្នុងបញ្ជីគ្រប់គ្រងរបស់កងឯកភាព ។ ពាក្យស្នើសុំត្រូវបញ្ជាក់ទទួលស្គាល់របស់មេបញ្ជាការកងឯកភាពហើយផ្ញើជូនមកការិយាល័យទី ៤ (ផ្នែកអាវុធ) រៀបចំសំណុំបែបបទជូនអគ្គសេនាធិការពិនិត្យសំរេច ដោយឆ្លងតាមរយៈការិយាល័យទី ១ អគ្គសេនាធិការពិនិត្យ និង បញ្ជាក់ទទួលស្គាល់ យោធិនទាំងនោះ ។

យោធិនទាំងអស់មិនអនុញ្ញាតអោយប្រើប្រាស់អាវុធវែង ជាលក្ខណៈបុគ្គលឡើយ លើកលែងតែកងការពារថ្នាក់ដឹកនាំ និង បញ្ជាបេសកកម្ម ពេលចប់ភារកិច្ចត្រូវយកអាវុធទុកក្នុងកងឯកភាព មិន អនុញ្ញាតអោយយកអាវុធទុកតាមខ្លួនឡើយ ។

**ប្រការ ២** : អំពីសមត្ថកិច្ចចេញលិខិតអនុញ្ញាតប្រើប្រាស់ និង ដឹកជញ្ជូនអាវុធ និងជាតិផ្ទុះ គ្រប់ប្រភេទសំរាប់កងកម្លាំងនគរបាលជាតិ និង ជនស៊ីវិល :

ក–ស្នងការដ្ឋាននគរបាលខេត្ត ក្រុង និង រាជធានីភ្នំពេញ មានសិទ្ធិចេញលិខិតអនុញ្ញាតដឹក ជញ្ជូនបានតែក្នុងភូមិសាស្ត្រដែលខ្លួនទទួលខុសត្រូវ ។

ខ–ការដឹកជញ្ជូនឆ្លងកាត់ខេត្ត ក្រុង ស្នងការនគរបាលខេត្ត ក្រុងត្រូវសុំការអនុញ្ញាតពីក្រសួងមហាផ្ទៃ ។

**ប្រការ ៣** : អំពីសមត្ថកិច្ចចេញលិខិតអនុញ្ញាតប្រើប្រាស់ និង ដឹកជញ្ជូនអាវុធ និងជាតិផ្ទុះគ្រប់ ប្រភេទសំរាប់កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថជាតិ :

ក–ក្រសួងការពារជាតិ ចេញលិខិតអនុញ្ញាតអោយដឹកជញ្ជូនអាវុធ ជាតិផ្ទុះគ្រប់ប្រភេទចេញពី ឃ្លាំងយុទ្ធសាស្ត្ររបស់ក្រសួង ផ្តល់ជូនឃ្លាំងអគ្គសេនាធិការ ។

ខ-អគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ ចេញលិខិតអនុញ្ញាតអោយដឹកជញ្ជូនអាវុធ និង ជាតិផ្ទុះគ្រប់ប្រភេទដល់កងឯកភាព នៃកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ ពេលបើកចេញ ពីឃ្លាំង ។

គ-យោធភូមិភាគមានសិទ្ធិចេញលិខិតអនុញ្ញាតដឹកជញ្ជូនអាវុធ និងជាតិផ្ទុះគ្រប់ប្រភេទដល់កងពល និងតំបន់ប្រតិបត្តិការសឹករងដែលប្តូរទីតាំង និង ទៅប្រតិបត្តិការសឹកក្រៅភូមិសាស្ត្រ ។

ឃ-កងពល និង តំបន់ប្រតិបត្តិការសឹករង មានសិទ្ធិចេញលិខិតដឹកជញ្ជូនបានតែក្នុងភូមិ សាស្ត្រដែលខ្លួនទទួលខុសត្រូវ ។

**ប្រការ ៤** : ចំពោះអាវុធពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម ផ្នែកបច្ចេកទេសគ្រប់គ្រងអាវុធ និង ជាតិផ្ទុះ ក្រសួងមហាផ្ទៃ និង ក្រសួងការពារជាតិ ត្រូវសហការស្រាវជ្រាវតាមសំណូមពរជាក់ស្តែង របស់ក្រសួង មហាផ្ទៃ ឬក្រសួងការពារជាតិ ។

**ប្រការ ៥** : ហាមមិនអោយយកអាវុធវែង ខ្លី ជាតិផ្ទុះគ្រប់ប្រភេទចូលរាជធានីភ្នំពេញ ហើយត្រូវរក្សាទុកនៅប៉ុស្តិ៍ ត្រួតពិនិត្យអាវុធ និង ជាតិផ្ទុះតាមការកំណត់ដូចខាងក្រោមនេះ ÷

**ក—តាមផ្លូវគោក** :

១-ផ្លូវជាតិលេខ ១ (ចំណុចសង្កាត់និរោធ ខណ្ឌមានជ័យ) ។

២-ផ្លូវជាតិលេខ ៣ (ចំណុចសង្កាត់ពងទឹក ខណ្ឌដង្កោ) ។

៣-ផ្លូវជាតិលេខ ៤ (ចំណុចសង្កាត់ចោមចៅ ខណ្ឌដង្កោ) ។

៤-ផ្លូវជាតិលេខ ៥ (ចំណុចសង្កាត់ស្វាយប៉ាក ខណ្ឌឫស្សីកែវ) ។

៥-ផ្លូវជាតិលេខ ៦ អា (ចំណុចសង្កាត់ព្រែកលាប ខណ្ឌឫស្សីកែវ) ។

**ខ—តាមផ្លូវទឹក** :

-កំពង់ផែដឹកជញ្ជូនអ្នកដំណើរភ្នំពេញ ។

**គ—តាមផ្លូវដែក** :

-ស្ថានីយ៍រាជាយស្ម័យយានភ្នំពេញ ។

**ឃ—តាមផ្លូវអាកាស** :

-អាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង ។

ក្នុងករណីអាចអោយយកអាវុធ ចូលបានបើ ÷

-មានសំណូមពរយកអាវុធ ឬជាតិផ្ទុះមកធ្វើកោសល្យវិច្ច័យ ដោយមានលិខិតបញ្ជាក់ត្រឹមត្រូវពីអាជ្ញាធរមានសមត្ថកិច្ច ឬ

-មានភារកិច្ចចាំបាច់ការពារអភិបាល អភិបាលរងខេត្ត ក្រុង មេបញ្ជាការ មេបញ្ជាការរង យោធភូមិភាគ មេបញ្ជាការ មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករង និង ស្នងការ ស្នងការរង ដែលមកបំពេញការងារនៅភ្នំពេញ អាចអោយយកអាវុធខ្លីមួយចំនួនសមស្របចូលបាន ឬ

-មានបេសកកម្មឆ្លងកាត់រាជធានីភ្នំពេញទៅបំពេញបេសកកម្មនៅខេត្ត ឬក្រុងមួយផ្សេង ទៀត ។

-កងឯកភាពនៅក្នុងរាជធានីភ្នំពេញ ត្រូវវិលពីប្រតិបត្តិការក្រៅរាជធានីភ្នំពេញ ។

-កងឯកភាពដែលមានភារកិច្ចប្រតិបត្តិការ យុទ្ធដំណើរត្រូវការឆ្លងកាត់ រាជធានីភ្នំពេញ ត្រូវយកលិខិតបញ្ជាបេសកកម្មបង្ហាញដល់ភ្នាក់ងារជំនាញមានសមត្ថកិច្ចដែលត្រួតពិនិត្យនៅច្រកចូលរាជធានីភ្នំពេញ ដើម្បីអោយភ្នាក់ងារនៅច្រកនោះជូនដំណើរ អោយផុតពីរាជធានីភ្នំពេញ ។

ផ្លូវដែលបានកំណត់ខាងលើ មិនអនុញ្ញាតអោយយកអាវុធ ឬ ជាតិផ្ទុះឆ្លងកាត់ជាដាច់ខាត។

**ប្រការ ៦ :** មន្ត្រីនគរបាលជាតិ ឬមន្ត្រីយោធាណាដែលបានចេញលិខិតអនុញ្ញាត អោយប្រើប្រាស់អាវុធ និងជាតិផ្ទុះគ្រប់ប្រភេទផ្ទុយពីការកំណត់នៃ ប្រកាសអន្តរ ក្រសួងនេះ ត្រូវបណ្តេញចេញពីក្របខ័ណ្ឌ និង ផ្តន្ទាទោសតាមច្បាប់ ។

**ប្រការ ៧ :** ជនណាប្រើប្រាស់អាវុធ និងជាតិផ្ទុះគ្រប់ប្រភេទផ្ទុយពីបទបញ្ញត្តិនៃប្រកាសនេះ ត្រូវដកហូតអាវុធជាតិផ្ទុះនោះ និងត្រូវបញ្ជូនខ្លួនទៅតុលាការផ្តន្ទាទោសតាមច្បាប់ ។

**ប្រការ ៨** : លិខិតអនុញ្ញាតអោយប្រើប្រាស់អាវុធ និង ជាតិផ្ទុះគ្រប់ប្រភេទ មានសុពលភាព ១ ឆ្នាំ ចាប់ពីថ្ងៃចេញលិខិតអនុញ្ញាតអោយប្រើប្រាស់អាវុធ និងជាតិផ្ទុះនេះ ។

លិខិតអនុញ្ញាតអោយប្រើប្រាស់អាវុធ និង ជាតិផ្ទុះគ្រប់ប្រភេទចាស់មានសុពលភាពដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩៦ ។

**ប្រការ ៩** : នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ អគ្គសេនាធិការ និង គ្រប់ស្ថាប័នក្រោមឱវាទ ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ អភិបាលខេត្ត – ក្រុង មេបញ្ជាការយោធភូមិភាគ មេបញ្ជាការតំបន់ប្រតិបត្តិសឹករង ស្នងការនគរបាលខេត្ត–ក្រុង ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ

| | |
|---|---|
| សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | សហរដ្ឋមន្ត្រីក្រសួងការពារជាតិ |
| ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **ស ខេង យូ ហុកគ្រី** | **ទៀ បាញ់ ទា ចំរ៉ាត់** |

* * *

## ២ - អន្តរក្រសួង សាធារណការ និងដឹកជញ្ជូន សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មហាផ្ទៃ

រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ១៩៩៦

**ប្រកាសរួមលេខ : ២៨១ ប្រក.សក**

**ស្តីពីការបន្តផ្តល់ផ្លាកលេខរថយន្ត ចត្តុតស្លាំ**

**អន្តរក្រសួង សាធារណការ និង ដឹកជញ្ជូន**

**សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ - មហាផ្ទៃ**

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា